ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៦៨៧/២០-៩-២០០៥

សាលដីកា

លេខ:៣៩ក្រIVអ/២២-០២-២០១៣

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២២-២-២០១៣ ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់នៃរឿងព្រហ្មទណ្ឌលេខ:៦៨៧ ចុះថ្ងៃទី២០-៩-២០០៥ រវាង ៖

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ុន ហៅ ចិន តុលា ហៅ យ៉ា(ដើមបណ្តឹងឧទ្ធរណ៍) ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរយោធា កើតនៅភូមិទួលចំបក់ ឃុំបារាយ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted](រ) ម្តាយមិនស្គាល់ឈ្មោះ ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ទោសពីមុនគ្មាន ។

ឃុំខ្លួនថ្ងៃទី២៦.០១.២០០៥ លេខឃុំខ្លួន:១៥១

មេធាវីការពារលោកស្រី [redacted] រល័ក្ស

ត្រូវចោទពីបទ:ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៥-០២-២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ។ ១៩៨៧



Scanned with CamScanner

## ដំណើររឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥-០២-២០០៣ របស់ឈ្មោះ [redacted] បានប្តឹងពីជនល្មើស០៣នាក់ ស៊ីវិល បានដើរមកធ្វើសកម្មភាពប្លន់យកម៉ូតូខ្លួនម៉ាកC125 ពណ៌ផ្ទៃមេឃ នៅត្រង់ចំណុចមុខវិទ្យាល័យបាក់ទូក ផ្លូវ១៦៩ ក្នុងសង្កាត់វាលវង់ ខណ្ឌ៧មករា នៅថ្ងៃទី០៥.០២.២០០៣ វេលាម៉ោង១២និង៥០នាទី ។ ដោយនៅថ្ងៃទី០៥.០២.២០០៣ វេលាម៉ោង១២និង៥០នាទី ខ្លួនបានជិះម៉ូតូចេញពីផ្ទះមករៀននៅសាលាបាក់ទូក ពេលមកដល់សាលាបាក់ទូក ខ្លួនបានឈប់ម៉ូតូអង្គុយលេងជាមួយមិត្តភ័ក្រឈ្មោះ ថែម កាណាល់ ស្រាប់តែមានជនល្មើស០៣នាក់ស៊ីវិល ដើរមករកខ្លួន ហើយដកអាវុធខ្លីមួយដើមមិនស្គាល់ម៉ាក ភ្ជង់ឱ្យខ្លួនចេញពីម៉ូតូ ពេលនោះខ្លួនក៏រត់ចេញពីម៉ូតូ ហើយជនល្មើសបានប្លន់យកម៉ូតូខ្លួន ជិះទៅទិសខាងជើងបាត់តែម្តង ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៨៥(ង) ចុះថ្ងៃទី២៦-៧-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ហ៊ុន ហៅ ប៊ិន តុលា ហៅ យ៉ា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៦ឆ្នាំ(ប្រាំមួយឆ្នាំ) គិតបន្តពីសាលក្រមមុនលេខ:៨៤(ង) ចុះថ្ងៃទី០៥.០២.២០០៣ ពីបទ:ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៥.០២.២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ប្តឹងទាមទារសំណងការខូចខាត និង ជម្ងឺចិត្តទៅតុលាការរដ្ឋប្បវេណី ។

-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ [redacted] ហ៊ុន ហៅ ប៊ិន តុលា ហៅ យ៉ា កំបាំងមុខជនរងគ្រោះ [redacted] ទុកពេលប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១៨-១០-២០០៦ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ុន ហៅ ប៊ិន តុលា ហៅ យ៉ា (វត្តមាន)

-មេធាវីការពារលោកស្រី [redacted] វរល័ក្ស (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

១៩៨



Scanned with CamScanner

-ឈ្មោះ [redacted] ហ៊ិន ឆ្លើយថា: ខ្លួនប្តឹងទាស់ព្រោះរឿងនេះខ្លួនមិនបានប្រព្រឹត្តទេ ។ ឆ្នាំ២០០៣ ខ្លួនមិនបានប្រព្រឹត្តទេ ។ ពេលនោះគេវាយខ្លួនសន្លប់ ទើបគេសួរចម្លើយ ។ ខ្លួនមានសាលក្រមទាំងអស់៤ ។ កាំភ្លើងខ្លួនម៉ាកប៉េអាកុល ។ សំណូមពរសូមក្រុមប្រឹក្សាលើកលែងចោទប្រកាន់ ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: យល់ឃើញថាពេលសវនាការជនជាប់ចោទគ្មានភស្តុតាងអ្វីមកឲ្យសាលាឧទ្ធរណ៍ពិចារណាឡើយ ។ ទទួលបណ្តឹងទាស់លេខ:២៥ ចុះថ្ងៃទី៦.៥.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ិន ហៅ ប៊ិន តុលា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។ តម្កល់សាលដីកាព្រហ្មទណ្ឌលេខ:១៨(ជ) ចុះថ្ងៃទី១៦-១-២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

-មេធាវី [redacted] វរល័ក្ស ការពារឲ្យជនជាប់ចោទ សន្និដ្ឋានថា: ក្នុងរឿងនេះកូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ចម្លើយរបស់កូនក្តីខ្លួននៅប៉ូលីស គឺប៉ូលីសចាប់បង្ខំ ចំពោះកូនក្តីខ្លួនមានកាំភ្លើងមានច្បាប់ត្រឹមត្រូវ ព្រោះគាត់ជាសមត្ថកិច្ចក្នុងអង្គភាពចារកិច្ច ។ សូមក្រុមប្រឹក្សាពិចារណាលើមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង សូមក្រុមប្រឹក្សាលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍**

**យល់ឃើញថា៖**

១-បណ្តឹងទាស់លេខ:២៥ ចុះថ្ងៃទី៦-៥-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ិន ហៅ ប៊ិន តុលា ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ បាន ។

-មេធាវី [redacted] វរល័ក្ស ការពារសិទ្ធិឱ្យជនជាប់ចោទ ។

២-ចម្លើយរបស់ជនជាប់ចោទនាសវនាការនេះថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ សុំឲ្យរួចពីបទចោទ ។

៣-តាមចម្លើយឈ្មោះ [redacted] ហ៊ិន នៅការិយាល័យនគរបាលព្រហ្មទណ្ឌផ្តល់ឆ្លើយថា នៅថ្ងៃទីមិនចាំក្នុងខែកុម្ភៈ ២០០៣ ម៉ោងប្រហែល១១ម៉ ខ្លួននិងអាភ័ក្រ្ត, អារ័ក ដោយមធ្យោបាយថ្មើរជើង មានកាំភ្លើងK



Scanned with CamScanner

៥៩ មួយដើម បានប្លន់ម៉ូតូC125 ពណ៌កាប់ស្ពាំង ស៊េរី២០០៣ មួយគ្រឿងនៅមុខសាលាបាក់ទូក ដោយម្ចាស់ម៉ូតូកំពុងតែអង្គុយលើម៉ូតូ ។ ខ្លួនដកកាំភ្លើងភ្ជង់ ហើយ អាភ័ក្ត្រ ជាអ្នកយកម៉ូតូជិះទៅលក់នៅខេត្តកំពង់ចាម បាន៥០០ដុល្លា ។ ខ្លួនទទួលបាន១០០ដុល្លា ។ ចម្លើយរបស់ [redacted] ហ៊ុន ស៊ីសង្វាក់ទៅនឹងចម្លើយឈ្មោះ [redacted] សុធារី ជាជនរងគ្រោះថា ថ្ងៃ៥.២.២០០៣ ម៉ោង១២ម៉៥០ ខ្លួនកំពុងអង្គុយលេងលើម៉ូតូជាមួយ **ថែម កាណាល់** ស្រាប់តែមានជនល្មើស៣នាក់ ដើរមកដកអាវុធមួយដើមភ្ជង់ខ្លួនឲ្យចេញពីម៉ូតូ ហើយជនល្មើសបានយកម៉ូតូទៅបាត់ ។ ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ហ៊ុន ហៅ ប៊ិន តុលា ពីបទប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៥.២.២០០៣ ។

៤-សាលដីកាព្រហ្មទណ្ឌលេខ:១៨(ជ) ចុះថ្ងៃទី១៦-១-២០០៩ របស់សាលាឧទ្ធរណ៍ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងទាស់លេខ:២៥ ចុះថ្ងៃទី៦.៥.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ុន ហៅ ប៊ិន តុលា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ:១៨(ជ) ចុះថ្ងៃទី១៦-១-២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវី [redacted] វរល័ក្ស ។

បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

២០០



Scanned with CamScanner